# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**


លេខៈ ៤៧១/២៣ ក.ប/អ.ក/អ.ធ.ក/ព.ក

**ជម្រាបមក**

**លោក ម្ចាស់ ឬនាយកក្រុមហ៊ុន សាន់ ស៊ូ ហ្គាម៉ិន(វិស័យកាត់ដេរ)**

អាសយដ្ឋានៈ ឃុំខ្ចិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

**យោង** ៖ លិខិតចុះថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក ម្ចាស់ ឬនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៤០នាក់ (ស្រី ១១៨នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ២ ៥៣៩នាក់ (ស្រី ២ ២៣២នាក់) គិតចាប់ពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ ដោយកម្មករនិយោជិតត្រូវទទួលបានប្រាក់ឧបត្ថម្ភដូចខាងក្រោម៖

១. កម្មករនិយោជិតចំនួន ១៤០នាក់ (ស្រី ១១៨នាក់) ដែលព្យួររយៈពេល ២២ថ្ងៃ ក្នុងខែកក្កដា ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ដុល្លារអាម៉េរិក។

២. កម្មករនិយោជិតចំនួន ១៤០នាក់ (ស្រី ១១៨នាក់) ដែលព្យួររយៈពេល ៩ថ្ងៃ ក្នុងខែសីហា ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ២០ដុល្លារអាម៉េរិក។

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោក ម្ចាស់ ឬនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោក ម្ចាស់ ឬនាយក** បញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ និងត្រូវទទួលខុសត្រូវបង់ជូសកម្មករនិយោជិតទៅតាមចំនួនប្រាក់ឧបត្ថម្ភបានផ្ទេរជូនកម្មករនិយោជិត ដែលបានចូលធ្វើការមុនកំណត់។ ប្រសិនបើបញ្ចប់ការព្យួរកិច្ចសន្យាការងារលើសពី ១លើក **លោក** ត្រូវទទួលខុសត្រូវចេញប្រាក់ឧបត្ថម្ភជំនួសរាជរដ្ឋាភិបាលឱ្យទៅកម្មករនិយោជិតដែលនៅសល់រហូតដល់បញ្ចប់ការព្យួរកិច្ចសន្យាការងារ។

អាស្រ័យដូចនេះ សូម **លោក ម្ចាស់ ឬនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោក ម្ចាស់ ឬនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ ពុធ ៣រោច ខែ បឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣

**ត.ប. រដ្ឋមន្ត្រី**

**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**ខេម ប៊ុនឈាន**

**ចម្លងជូនៈ**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋបាលរាជធានី ខេត្ត